ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ២៧៦៥ ព.ណ.ស.ន.ល

ថ្ងៃ ... ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់១៥ ខែកក្កដា ឆ្នាំ២០១៨ នឹងត្រូវលក់ ៤.១១០រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៩៥០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់១៥ ខែកក្កដា ឆ្នាំ២០១៨** នឹងចុះមក ៣.៩៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៧៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) | |
|---|---|---|---|---|---|
| ១ | **Average MOPS** | | ០,៥០២៩ ដុល្លារ | | ០,៥៤២២ ដុល្លារ |
| ២ | ពន្ធ៖ | | ០,១៧៩១ ដុល្លារ | | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | | ០,០០០០ ដុល្លារ | |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | | ០,០៤០០ ដុល្លារ | |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | | ០,០២៩៦ ដុល្លារ | |
| ៣ | **PREMIUM** | | ០,២០ ដុល្លារ | | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | | ០,០៨៩៣ ដុល្លារ | | ០,០៨៤២ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៩៧០២ ដុល្លារ | | ០,៩២៦០ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | | ៣.៩៤២ រៀល | | ៣.៧៦២ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | | ០,៩៧ ដុល្លារ | | ០,៩៣ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | | ៣.៩៥០ រៀល | | ៣.៧៥០ រៀល |

សម្គាល់៖ អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលស្មើនឹង ៤ ០៦៣រៀល/ដុល្លារអាមេរិក

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង<br>EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង<br>DO 0.05% (USD/Barrel) |
|---|---|---|
| ២១ មិថុនា ២០១៨ | ៧៧,៨៣ | ៨៤,៧៣ |
| ២២ មិថុនា ២០១៨ | ៧៨,៦៦ | ៨៥,០១ |
| ២៥ មិថុនា ២០១៨ | ៧៩,៧៥ | ៨៥,៩៥ |
| ២៦ មិថុនា ២០១៨ | ៧៩,៦១ | ៨៥,៤៩ |
| ២៧ មិថុនា ២០១៨ | ៨០,២៩ | ៨៦,៥៥ |
| ២៨ មិថុនា ២០១៨ | ៨១,៦២ | ៨៧,៦៩ |
| ២៩ មិថុនា ២០១៨ | ៨២,០០ | ៨៨,០៤ |
| **មធ្យមភាគ ៧ថ្ងៃ** | **៧៩,៩៦៥៧** | **៨៦,២០៨៦** |
| **មធ្យមភាគ (ដុល្លារ/លីត្រ)** | **០,៥០២៩** | **០,៥៤២២** |

សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការប្រាប់។